# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## **ការផ្តល់ដំណឹងអំពីសិទ្ធិផ្សេងៗ ក្រោមច្បាប់ FERPA សម្រាប់ សាលាបឋមសិក្សា និង វិទ្យាល័យ**

## **២០១៣-២០១៤**

សិទ្ធិនៃការសិក្សា និងច្បាប់រក្សាការសម្ងាត់ របស់ក្រុមគ្រួសារ - The Family Educational Rights and Privacy Act (FERPA) ផ្តល់សិទ្ធិដល់មាតាបិតា និងសិស្សានុសិស្សណាដែលមានអាយុ១៨ឆ្នាំឡើងទៅ ("សិស្សានុសិស្សដែលមានសិទ្ធិ") នូវសិទ្ធិដែលទាក់ទងនឹងឯកសារសិក្សាផ្សេងៗរបស់សិស្ស។ សិទ្ធិទាំងនេះមាន៖

(១) សិទ្ធិ ពិនិត្យមើល និងពិនិត្យឡើងវិញ នូវឯកសារសិក្សារបស់សិស្ស ក្នុងកំឡុងពេល៤៥ថ្ងៃ ចាប់ពីថ្ងៃដែលសាលាទទួលសំណើសុំមើលឯកសារ។

មាតាបិតា ឬសិស្សានុសិស្សដែលមានសិទ្ធិ គប្បីដាក់ពាក្យស្នើ សរសេរជាលាយល័ក្ខអក្សរទៅ នាយកសាលា [ឬបុគ្គលិកដែលទទួលខុសត្រូវ នៅសាលា] បញ្ជាក់ពីឯកសារដែលខ្លួលចង់ពិនិត្យមើល។ បុគ្គលិកដែលទទួលខុសត្រូវនៅសាលា នឹងធ្វើការរៀបចំ ហើយផ្តល់ដំណឹងទៅមាតាបិតា ឬ សិស្សដែលមានសិទ្ធិអំពី ពេលវេលា និង ទីកន្លែង ដែលអាចពិនិត្យមើលឯកសារទាំងនេះ។

(២) សិទ្ធិស្នើសុំឲ្យមានការកែប្រែឯកសារសិក្សារបស់សិស្ស ដែលមាតាបិតា ឬ សិស្សដែលមានសិទ្ធិ ជឿថាមានការខុសឆ្គង។

មាតាបិតា ឬសិស្សានុសិស្សដែលមានសិទ្ធិ អាចសុំឲ្យសាលាកែប្រែឯកសារដែលពួកគេ ជឿថាមានការខុសឆ្គង។ ពួកគេគួរសរសេរលិខិតទៅនាយកសាលា [ឬបុគ្គលិកដែលទទួលខុសត្រូវនៅសាលា] បញ្ជាក់ឲ្យបានច្បាស់លាស់នូវជំពូកនៃឯកសារដែលពួកគេចង់ឲ្យកែប្រែ និងបញ្ជាក់ពីចំណុច ដែលមិនត្រឹមត្រូវ។ បើសិនជាសាលាសម្រេចថាមិនកែប្រែឯកសារសិក្សាតាមការស្នើសុំរបស់ មាតាបិតា ឬសិស្សដែលមានសិទ្ធិទេនោះ សាលានឹងជម្រាបទៅ មាតាបិតា ឬសិស្សដែលមានសិទ្ធិ នូវការសម្រេចនេះ ហើយណែនាំពួកគេឲ្យដឹងអំពីសិទ្ធិរបស់ពួកគេ ក្នុងការប្តឹងតវ៉ា ដែលទាក់ទងនឹងសំណើនៃការកែប្រែឯកសារនេះ។ ព័ត៌មានបន្ថែមដែលទាក់ទងនឹងវិធីប្តឹងតវ៉ា នឹងត្រូវគេផ្តល់ជូន មាតាបិតា ឬសិស្សដែលមានសិទ្ធិ នៅពេលដែលគេជម្រាបអំពីសិទ្ធិនៃការប្តឹងតវ៉ា។

(៣) សិទ្ធិយល់ព្រមឲ្យបញ្ចេញព័ត៌មានផ្ទាល់ខ្លួន ដែលមាននៅក្នុងឯកសារសិក្សារបស់សិស្ស វៀរលែងតែក្នុងករណីណាដែលច្បាប់ FERPA អាចអនុញ្ញាតឲ្យបញ្ចេញព័ត៌មាន ដោយមិនបាច់មានការយល់ព្រម។

មានករណីលើកលែងមួយ ដែលគេអនុញ្ញាតឲ្យបញ្ចេញព័ត៌មានដោយមិនចាំបាច់មានការយល់ព្រម គឺការផ្តល់ព័ត៌មានដល់បុគ្គលិកសាលា ដែលទាក់ទងដល់ការអប់រំដែលត្រឹមត្រូវតាមច្បាប់។ បុគ្គលិកសាលាគឺជាអ្នកដែលសាលាបានជួលឲ្យធ្វើជា អភិបាល អ្នកដឹកនាំ គ្រូបង្ហាត់បង្រៀន ឬបុគ្គលិកជំនួយការ (រួមមាន បុគ្គលិកផ្នែក សុខភាព ឬសុខាភិបាល និង ភ្នាក់ងារខាងអាជ្ញាធរ) សមាជិកគណកម្មការសាលា បុគ្គល ឬ ក្រុមហ៊ុន ដែលសាលាមានកិច្ចសន្យាឲ្យធ្វើកិច្ចការពិសេស (ដូចជា មេធាវី អ្នកត្រួតត្រាបញ្ជី ទីប្រឹក្សាផ្នែកសុខាភិបាល ឬ អ្នកព្យាបាល) ឬមាតាបិតា ឬសិស្សដែលជាសមាជិកគណកម្មការជាផ្លូវការ ដូចជាគណកម្មការផ្នែក ដាក់វិន័យ ឬ ទទួលបណ្តឹង ឬជាជំនួយការដល់បុគ្គលិកសាលាដ៏ទៃទៀតក្នុងការបំពេញភារកិច្ចរបស់ពួកគាត់។

បុគ្គលិកសាលាមានមូលហេតុត្រឹមត្រូវ បើសិនជាពួកគាត់ត្រូវការពិនិត្យឲ្យបានហ្មត់ចត់នូវឯកសារសិក្សា គឺដើម្បីបំពេញនូវការទទួលខុសត្រូវលើកិច្ចការងាររបស់ពួកគាត់។

បើមានការស្នើសុំ សាលានឹងបញ្ជូនឯកសារសិក្សាដោយមិនចាំបាច់មានការយល់ព្រម ឲ្យទៅបុគ្គលិកនៃក្រសួងអប់រំដ៏ទៃទៀត ដែលសិស្ស ប្រាថ្នា ឬ មានបំណងចង់ ចុះឈ្មោះចូលរៀននៅទីនោះ។ [**កំណត់សម្គាល់៖ ច្បាប់** FERPA តម្រូវឲ្យក្រសួងអប់រំ ព្យាយាមជម្រាបទៅមាតាបិតា ឬសិស្សានុសិស្ស តាមការគួរ អំពីសំណើសុំឯកសារ វៀរលែងតែក្នុងករណីដែលមានចែងនៅក្នុងលិខិតជូនដំណឹងប្រចាំឆ្នាំរួចហើយ ថាក្រសួងនឹងបញ្ជូនព័ត៌មានឲ្យទៅតាមការស្នើសុំ។]

(៤) សិទ្ធិដាក់បណ្តឹងទៅ ក្រសួងអប់រំប្រចាំសហរដ្ឋ (U.S. Department of Education) ដែលទាក់ទងនឹងការមិនអនុវត្តតាមច្បាប់ FERPA ដោយ *ក្រសួងអប់រំ*។ ឈ្មោះ និងអាស័យដ្ឋាន របស់ការិយាល័យចាត់ចែងច្បាប់ FERPA គឺ៖

Family Policy Compliance Office
U.S. Department of Education
400 Maryland Avenue, SW
Washington, DC 20202-590

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer